# ការខិតខំបញ្ចប់សំណុំរឿង០០២
# តាមរយៈការបង្កើតអង្គជំនុំជម្រះសាលាដំបូងទី២

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចធ្វើមោឃភាពលើ ដីកាបំបែកកិច្ចដំណើរនីតិវិធី(ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១) សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ(ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) សេចក្តីសម្រេចដែលរងការជំទាស់(ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២) និងអនុស្សរណៈទាំងអស់ ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ។ បើពិនិត្យមើលសេចក្តីសម្រេចរបស់តុលាការកំពូល មូលហេតុសំខាន់បំផុតដែលនាំឲ្យសម្រេចធ្វើមោឃភាពទៅលើដីកាសម្រេចបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង គឺដោយសារតែវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ពុំបានឆ្លុះបញ្ចាំង ឬ តំណាងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលឲ្យបានគ្រប់គ្រាន់ ។ គួរបញ្ជាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះបានចោទប្រកាន់ជនជាប់ចោទ នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយចំនួន ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទប្រល័យពូជសាសន៍លើជនជាតិចាមនិងវៀតណាម និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។ ចំពោះដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានវិសាលភាពជំនុំជម្រះតែបទល្មើសមួយចំនួនក្នុងចំណោមបទល្មើសផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែប៉ុណ្ណោះ ។ ចំណែកបទប្រល័យពូជសាសន៍លើជនជាតិចាម និងវៀវណាម និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺពុំត្រូវបានយកមកជំនុំជម្រះក្នុងសំណុំរឿង០០២/០១ឡើយ ។ ថ្វីត្បិតអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា បទចោទប្រកាន់ទាំងនេះនឹងត្រូវយកទៅជំនុំជម្រះនៅក្នុងដំណាក់កាលក្រោយៗ បន្ទាប់ពីសំណុំរឿង ០០២/០១ ត្រូវបានជំនុំជម្រះចប់សព្វគ្រប់ និងចេញសាលក្រមរួចហើយ ប៉ុន្តែរហូតមកដល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងនៅតែពុំទាន់អាចប្រមើលមើលឃើញពេលវេលាជាក់លាក់ណាមួយ ដើម្បីធ្វើការជំនុំជម្រះទៅលើបទល្មើសទាំងនេះឡើយ ។ ជាងនេះទៅទៀត ទោះបីសំណុំរឿង០០២/០១ អាចនឹងត្រូវបានជំនុំជម្រះចប់ក្នុងពេលឆាប់ៗនេះក្តី ប៉ុន្តែអង្គជំនុំជម្រះប្រហែលជាត្រូវចំណាយពេលច្រើនទៀត ដើម្បីរៀបចំ និងប្រកាសសាលក្រមលើសំណុំរឿងនេះ ។ តាមបទពិសោធន៍របស់អង្គជំនុំជម្រះក្នុងការរៀបចំ និងចេញសាលក្រមក្នុងសំណុំរឿង ០០១ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺអង្គជំនុំជម្រះសាលាដំបូងបានចំណាយរយៈពេល ៨ខែ គិតចាប់ពីថ្ងៃសវនាការសន្និដ្ឋានបញ្ចប់ការដេញដោលរហូតដល់ថ្ងៃប្រកាសសាលក្រម ចំណែកអង្គជំនុំជម្រះតុលាការកំពូលបានចំណាយពេលជាង

១០ខែ ក្នុងការរៀបចំ និងចេញសាលដីកា ។ ប្រហែលមូលហេតុនេះហើយដែលនាំឲ្យអង្គជំនុំជម្រះនៃតុលាការកំពូលផ្តល់អនុសាសន៍ឲ្យបង្កើតអង្គចៅក្រមជំនុំជម្រះថ្មីមួយផ្សេងទៀតនៅសាលាដំបូង ដើម្បីជំនុំជម្រះលើបទល្មើសដែលនៅសល់ទាំងនេះ បន្ទាប់ពីបញ្ចប់សវនាការសួរដេញដោលលើសំណុំរឿង០០២/០១ ។ ពោលគឺអង្គជំនុំជម្រះទី២នេះ នឹងចាប់ផ្តើមធ្វើការជំនុំជម្រះលើបទល្មើសដែលនៅសល់ នៅខណៈពេលដែលអង្គជំនុំជម្រះទីមួយ កំពុងរៀបចំសាលក្រមលើសំណុំរឿង០០២/០១ (ដែលអង្គជំនុំជម្រះអាចនឹងត្រូវចំណាយពេលប្រហាក់ហែល ឬច្រើនជាង បើធៀបទៅនឹងការរៀបចំ និងប្រកាសសាលក្រមក្នុងសំណុំរឿង០០១) ។ នេះគឺជាការអនុវត្តន៍ដ៏មានប្រសិទ្ធិភាពមួយ បើពិនិត្យមើលទៅលើស្ថានភាពសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង០០២ ។

ដូច្នេះការសម្រេចបង្កើតអង្គជំនុំជម្រះថ្មីមួយផ្សេងទៀត ដើម្បីធ្វើការជំនុំជម្រះលើបទចោទដែលនៅសល់ ក្នុងអំឡុងពេលដែលអង្គជំនុំជម្រះសាលាដំបូងទី១កំពុងធ្វើការរៀបចំសាលក្រមលើសំណុំរឿង០០២/០១ គឺបង្ហាញឲ្យឃើញថា តុលាការកំពុងខិតខំប្រឹងប្រែងថែមមួយកម្រិតទៀត ដើម្បីធានាថាបទចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយ នឹងត្រូវបានជំនុំជម្រះចប់សព្វគ្រប់ ទោះបីស្ថានភាពបច្ចុប្បន្នតុលាការកំពុងមានភាពខ្វះខាតថវិការក៏ដោយ ។

**ចាន់ ប្រាថ្នា**

**ពិនិត្យដោយ ឆាំង យុ**